# សេចក្តីប្រកាសទទួលពាក្យស្នើសុំ
# ចូលរួមសិក្ខាសាលារចនាម៉ូតឆាកសម្តែង
## SET DESIGN WORKSHOP

អង្គការសិល្បៈខ្មែរអមតៈ សហការជាមួយមហាវិទ្យាល័យតូរ្យតន្ត្រីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាលាជាតិនៃសិល្បៈតុបតែង (École Nationale Supérieure des Arts Décoratifs) មកពីប្រទេសបារាំង មានសោមនស្ស សូមប្រកាសទទួលពាក្យស្នើសុំចូលរួម “សិក្ខាសាលារចនាម៉ូតឆាកសម្តែង” ដែលនឹងប្រព្រឹត្តទៅនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ **រយៈពេល ៤ ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោង ៨ ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់។**



*រូបភាពដោយ សំ សុខារុណ*

សិក្ខាសាលានេះផ្តោតទៅលើបួនចំនុចសំខាន់ៗ៖

១. ការគិតពីការតុបតែងឆាកភ្ជាប់ទៅនឹងទីកន្លែង (Thinking the Set Design in link with the venue)

២. ទំនាក់ទំនងរវាងខ្លួនប្រាណនិងឆាក (The relationship between body and space)

៣. ការតុបតែងភ្លើង (Set Design in relationship with Light)

៤. ទីកន្លែងសាធារណៈ (The place of the audience)

ទស្សនីយភាពសម្តែងរបស់អង្គការសិល្បៈខ្មែរអមតៈដែលមានឈ្មោះថា **“ត្រៃឋាន”** នឹងត្រូវយកមកធ្វើជាករណីសិក្សា និងជាសម្ភារៈសម្រាប់សិក្ខាសាលានេះ។ បន្ទាប់ពីចប់សិក្ខាសាលា សិក្ខា-កាមក៏នឹងទទួលបានលិខិតបញ្ជាក់ពីការចូលរួមផងដែរ។ **សិក្ខាសាលានេះ ធ្វើឡើងជាភាសាអង់គ្លេសអមដោយបំណកប្រែជាភាសាខ្មែរ។**

## អំពីលក្ខខណ្ឌ

សិក្ខាសាលានេះសម្រាប់សិក្ខាកាមចំនួន ៩ នាក់ ដែលមានជំនាញ ល្ខោន តន្ត្រី របាំ កុន ស្ថាបត្យកម្ម រចនាខាងក្នុង និងរចនាសម្លៀកបំពាក់ជាដើម ដែលមានបំណងចង់អភិវឌ្ឍន៍ជំនាញ និងគុណភាពស្នាដៃរបស់ខ្លួនបន្ថែមទៀត។ បេក្ខជនត្រូវមានៈ

- មានបទពិសោធន៍ការងារលើជំនាញខាងលើឬពាក់ព័ន្ធ យ៉ាងតិច ៣ ឆ្នាំ។
- អាចចូលរួមពេញលេញក្នុងកម្មវិធីទៅតាមកាលវិភាគដែលបានកំណត់ រួមទាំងទ្រឹស្តីនៅក្នុងថ្នាក់ និងចុះកម្មសិក្សានៅពេលសម្តែងពេលយប់។

យើងប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីអាយុ ពិការភាព ជនជាតិដើមភាគតិច ភេទ អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា និងសង្គមសេដ្ឋកិច្ចឡើយ។ យើងសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ដែលមានសំឡេងតិច ហើយយើងនឹងផ្តល់ការគាំទ្រអាស្រ័យលើតម្រូវការ និងភាពចាំបាច់ (ទៅដល់បេក្ខជនដែលទទួលបានភាពជោគជ័យ)។

## អំពីការដាក់ពាក្យ

សូមភ្ជាប់មកជាមួយ ១. **ប្រវត្តិរូបសង្ខេបមិនលើសពី ៣ ទំព័រ (CV) និង ២. គំរូសម្ភារៈការងារមួយចំនួនរបស់អ្នក (វីដេអូ ឬរូបថតការងាររបស់អ្នក)**។

សូមផ្ញើពាក្យស្នើសុំមកកាន់ **ការិយាល័យអង្គការសិល្បៈខ្មែរអមតៈ**

- **អាសយដ្ឋានៈ** ១២៨ G៩ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ
- **ទូរសព្ទៈ** ០២៣ ៩៨៦ ០៣២
- **ឬផ្ញើមកកាន់** sokim@cambodianlivingarts.org
- **ត្រឹមម៉ោង ៥ ល្ងាច ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩។**

ក្នុងករណីបេក្ខជនមានបញ្ហាលំបាកក្នុងការរៀបចំប្រវត្តិរូបសង្ខេប ឬចម្ងល់នានា សូមទាក់ទងស្វែងរកជំនួយពីក្រុមការងារយើងរៀងរាល់ម៉ោងធ្វើការ ចន្ទ-សុក្រ (ម៉ោង ៨.០០ព្រឹក ដល់ម៉ោង ៥.៣០ល្ងាច) តាមរយៈលេខទូរសព្ទ ០១១ ៤៦០ ៩០០ ឬ sokim@cambodianlivingarts.org។